បន្ទាប់ពី

ភាពងងឹតគឺមាន

ពន្លឺ

(After Darkness Light)

និពន្ធ & និងគូររូបដោយ៖

Paul Cox

บราม่า
ภาพยนตร์ดีมาน
ภาค 2

POST TENEBRAS LUX

បទពិសោធន៍ភាពងងឹតគីមាន



PAUL COX

www.paulcoxillustration.com

និពន្ធ និងរចនាគម្របសៀវភៅដោយ៖ លោកគ្រូ Paul Cox

© ២០១៦, ២០២០ រក្សាសិទ្ធិដោយ៖ លោកគ្រូ Paul Cox

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យផ្នែកណាមួយនៃសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញដោយគ្មានការអនុញ្ញាតឡើយ។
សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកនិពន្ធ៖ www.paulcoxillustration.com

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ\ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក វ៉ែល ណាថាន, លោក ខែម បូឡុង, លោកស្រី ថាវ ប៊ុនរី, កញ្ញា ជុំ ចាន់ដារ៉ា, លោកគ្រូ លូកា ស្មីត, អ្នកគ្រូ សេង សុខា, កញ្ញា អៀង ដាលីន, លោកស្រី ឡូញ ស្រីរដ្ឋ, និងលោក ប៊ុន ដេត
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និង លោក ខែម បូឡុង

ព័ត៌មានបន្ថែមនៅ៖ plovpit.com/afterdarknesslight

សម្រាប់៖ Stephanie, Donovan, Bailey,

McKenna, និង Harper

ផ្នែកទី១៖

លោកគ្រូ ម៉ៃធិន លូសើរ

និង

សម័យកំណែទម្រង់

នៅឆ្នាំ ១៤១៥ គេបានដុតលោកគ្រូ យូន ហើស៍ (Jan Hus) ដោយសារគាត់ជឿថាព្រះគម្ពីរមានអំណាចជាង អំណាចនៃក្រុមជំនុំកាតូលិក។ ខណៈពេលដែលគាត់កំពុងតែឆេះ មានគេជឿថាគាត់បានមានប្រសាសន៍ដូចតទៅ៖ «ឥឡូវនេះពួកឯងកំពុងតែដុតសត្វទា [ក្នុងភាសាបូហីមាន (Bohemian) ពាក្យ “ហើស៍” ដែលជាឈ្មោះរបស់លោកគ្រូ មានន័យថា “សត្វទា”] ប៉ុន្តែ មួយសតវត្សរ៍ក្រោយមក ពួកឯងនឹងទទួលបានសត្វក្ងានដែលឯងនឹងមិនអាចអាំង ឬស្ងោរវាបានឡើយ។» ប្រមាណជាង ១០២ ឆ្នាំបន្ទាប់ពីលោកគ្រូ ហើស៍ បានប្រកាសបែបនោះ លោកគ្រូ ម៉ាធិន លូសើរ បានបិទនិក្ខេបបទ ៩៥ របស់គាត់លើទ្វារនៃក្រុមជំនុំនៅឯទីក្រុង វិឌតិនបើហ្គ (Wittenberg) ដែលការនោះ បង្កឲ្យសម័យកំណែទម្រង់បានចាប់ផ្តើមឡើង...

ទោះបើលោក ហាស៍ លូសើរ (Hans Luther) មានវណ្ណៈតូចទាបក៏ដោយ ក៏គាត់ខំប្រឹងធ្វើការពីហានៈជាអ្នកក្រី-ក្រហូតដល់ក្លាយជាអ្នកមានដោយសង្ឃឹមថាអាចបង់ថ្លៃសាលារៀនសម្រាប់កូនច្បងគាត់រៀននៅសាលាច្បាប់។ ជាលទ្ធផល តាមរយៈការធ្វើជាមេធាវី នោះគាត់រំពឹងថាលោក ម៉ាធិន នឹងអាចមើលថែឪពុកម្តាយខ្លួនពេលដែលពួកគាត់ចាស់ទៅ។ នៅឆ្នាំ ១៥០៥ បន្ទាប់ពីលោក ម៉ាធិន បានចូលរៀនសាលាច្បាប់ហើយ គាត់ក៏បានធ្វើដំណើរជិតភូមិ ស្តូឌធើនហៃម (Stotternheim) ដែលពេលនោះគាត់ក៏បានប្រឈមមុខនឹងព្យុះភ្លៀងយ៉ាងខ្លាំង។ ការជះឥទ្ធិពលពី ព្យុះភ្លៀងមួយនេះនឹងបំផ្លាស់បំប្រែជីវិតគាត់ជារៀងរហូត...

បទពិសោធន៍ ភាពងងឹតគឺមានពន្លឺ

លោកគ្រូ ម៉ែធិន លូសើរ & វីថីនៃសម័យកំណែទម្រង់




ឆ្នាំ ១៤១៤
ទីក្រុងយូនស្ទីនស៍ (Constance)
ប្រទេសអាល្លឺម៉ង់
ទាក់ទងនឹងភាព
ខុសឆ្គងទាស់នឹង
ក្រមវិន័យ...
...នោះសតិសម្បាដញ្ជះរបស់
ខ្ញុំនឹងមិនអនុញ្ញាតឲ្យខ្ញុំលះប
លម្ដីខ្លួនវិញឡើយ។
លុះត្រាតែខ្ញុំយល់ច្បាស់
តាមរយៈបទគម្ពីរ...
អា ឃួន ហឺស៍!
ឥឡូវអញកាត់ក្ដី
ឯងឱ្យ...
ងាប់!


អាឧលង្គង
ខ្ញុំធ្វើមិនបានទេ
អាឧលង្គង
បើឯងគ្រាន់តែលេបសម្ដីវិញ
នោះអញអាចនឹង
រំដោះឯងបាន!


ថ្ងៃនេះ ពួកឯងនឹងចំអិនសាច់ខ្ញុំ!
ប៉ុន្តែ ១០០ ឆ្នាំបន្ទាប់ពីនេះ
ឯងនឹងឧទ្ទូលបានសេចក្តីសន្យាមួយ
...តែចុងក្រោយ ខ្ញុំនឹងអាច ទាំងអស់គ្នា
ឬក៏ស្ទើរតែបានផង!


ឆ្នាំ ១៤០៤
ទីក្រុងស្តុកខលឺមហាម (Stotternheim)
ប្រទេសអាល្លឺម៉ង់
ក្មេងតែ ទៅរកកន្លែង
ស្រកសិន
ចុច! ព្យុះឥឡូវលឺយ!



ជួយខ្ញុំផង
លោកឃាយ អេន!!
ដើងដើង!
ប្រសិនបើខ្ញុំរួចផុត
ពីព្យុះមួយនេះ សោះខ្ញុំ
នឹងទៅបួស


ទីក្រុងអែរហ្វឺត (Erfurt)
ប្រទេសអាល្លឺម៉ង
ត៊ុក!
ត៊ុក!!
ត៊ុក!!!
ខ្ញុំជាត់សេះ
ខ្ញុំសាឃ
...សាឃ...
ខ្ញុំក៏ចង់ចូលក្រុម
រាបស់អ្នកផង
ដែរ


ម៉ែវ៉ាមើលចុះ! កូនប្រុសយើង
ពិលអនាគតវាមេធាវី!
យើងអាចនិយាយ
ភ្លាបានល្អ?
ថ្ងៃនេះសត្វក្ងាន វ៉ាឃ្លាន
ខុសពីធម្មតា។
និយាយសោះទៅវិញ។
ខណៈសោះពិលកូនកំពុងតែរិះសោះពិតមើក្រែង
ស្នូរឆើនហែម មានព្យុះភ្លឺធំមួយបានកើតឡើង។
មានរន្ទះបាញ់ពិតកូន លើយកូនក៏ធ្លាក់ពីលើសោះ។
កូនខ្លាចថានឹងបាត់បង់ជីវិត
ពីច្រេះក៏បានល្បួចទៅការព្រះ
ជាម្ចាស់ថា ប្រសិនបើព្រះ
អង្គសង្គ្រោះកូន។
ល្បួចថាម៉េច?
កូនបានបួសជាមួយនឹងក្រម
លង្ឃឈោកគ្រូ អប្តស្ចឹន។
លង្ឃឮម៉ែថាវ៉ាមិនមែនជាការ
ស្រមើលស្រមៃ ឬក៏ជាការ
ជោកបញ្ឆោតទៅចុះ។


ញោមមកនេះធ្វើអី?
តើញោមកំពុងស្វែងរកអ្វី?
ការុណាវត់ ប៉ុន្តែមិនអាចគេចផុតពីសេចក្តីត្រូវរបស់ព្រះសាម្ចាស់ទៀតនឹងពីតឡើង!
សាច្រើនថ្ងៃហើយ ការុណាត្រូវយកមុខនឹងអំពើបាបខាងៗ សាច់ឈាមនឹងឆ្អឹងអាក្រក់...
ការុណាចង់មានសេរីភាព...
តើធ្វើដូចម្តេចឲ្យការុណាទទួលបានទុក្ខវិញ?
នេះហើយគឺជាអ្វីដែលការុណាកំពុងស្វែងរក។
ល្អណាស់!
ពិធីការរបស់ញោមនឹងចាប់ផ្តើមនៅម៉ោង ២:00 ថ្ងៃក្រោយ។


និស្ស័យខាងសាច់ឈាមខ្ញុំខ្លាំងណាស់
ប៉ុន្តែខ្ញុំផ្ទាល់ឈ្មោះណាស់។ រាល់ថ្ងៃខ្ញុំ
ឃើញអំពើបាបខ្ញុំគ្រប់ពេលៗ តារាងនៃ
អំពើបាបខ្ញុំកាន់តែកើនឡើងៗ សូម្បីតែ
ក្នុងពេលដែលខ្ញុំកំពុងតែនិយាយឥឡូវ
នេះក៏ដោយ...
ចិត្តខ្ញុំតែងតែទៅដោយអំនួត...
កំហឹងឆេះក្តៅនៅក្នុងខ្លួនខ្ញុំ...
ខ្ញុំចង់បានថែមទៀត លើសាងអ្វីដែល
ខ្ញុំបានទទួលៗ
ពេលខ្ញុំអធិស្ឋាន ខ្ញុំតែងតែបែក
អារម្មណ៍...
ក្នុងកំនិតរបស់ខ្ញុំមានតែងតែដោយភាព
ច្រណែន ភាពត្រេកត្រអាល និងការ
ស្អប់ប្រមាថគ្រប់បែបយ៉ាង!
អស់ពីរម៉ោងហើយ។ ទាំងនេះគឺ
ដាកំហាសតូចតាចតែប៉ុណ្ណោះ។
ត្រឡប់មកវិញពេល
ដែលឯង ឯងមានអំពើ
បាបមែនទែន
ដើម្បីលន់តួ។
កំហាសតូចតាច? មិនសូវច្បាស់ទេ ក្មាន
អំពើបាបណាដែលដាអំពើកំប៉ិកកំប៉ុក
ទាស់នឹងព្រះវិបរិសុទ្ធ ដែលតម្រូវឲ្យ
មានការស្តាប់បង្គាប់ដ៏ល្អឥតខ្ចោះ!
ខ្ញុំខ្លាចថា ខ្ញុំនឹងមិនអាចវាកចេញ
ទុរពីអ្នកភាពក្នុងខ្លួនខ្ញុំបានឡើយ។


ពិតជាមានពរមែនវិលត្រូវជាន
ត្រើលផើលឱ្យធ្វើជាអ្នកធម្មយាត្រា!
មែន ពិតមែន!
ខ្ញុំអន្ទះសាចង់ទៅលេងឱ
ទីក្រុងចិនលុទ្ធណាស់!
ទីក្រុងផើហ្គុត
ចូលសាធ្លីម៉ែ
ឆ្នាំ ១៩១១
ទីក្រុងវ៉ូម
មើលណា! ទីក្រុងវ៉ូម!


ទីក្រុងនេះគឺជាទីកន្លែងដ៏អាក្រក់ណាស់!
ពួកសង្ឃចូលចិត្តដើរលេងជាមួយស្រីពេស្យា។ ធ្វើពិធីបុណ្យក្រីក្រសាសនា ៥ ដងក្នុងមួយថ្ងៃទុកជាមុខរបរ។ បើយលក់លិខិតលោះបាបក៏ទុកជាការចំណេញ!
ទីបំផុតលើងទៅទីលំដាប់
ការត់ចេញ ១០០០ ឆ្នាំសម្រាប់បុគ្គលដែលលោភអ្នកស្រឡាញ់ដែលកំពុងនៅស្ថានឋរកៗ
អធិស្ឋានមួយដង
សម្រាប់មួយឆ្នាំបាន ។
មនុស្សសុចរិតនឹងរស់ដោយជំនឿ។
ប្រសិនបើមានស្ថានឋរកមែន នោះទីក្រុងរ៉ូមនឹងត្រូវបានលង់លិចទាំងបើយ។


ឆ្នាំ ១៤១២ ទីក្រុងវីឌតិនបើប្ត
គេបានបញ្ជូនលោកគ្រូ ម៉ឺធិន ទៅទីក្រុង
វីឌតិនបើប្ត
តើមនុស្សសុចរិតនឹងរស់
ដោយសារអ្វីទៀតដោយ
រចៀបណា?
ការគ្នាទទួលបានលញ្ជាបីត្រង្វាក់បណ្តិត
ផ្នែកទេវវិទ្យាៗ
លើយគ្នាឡូវគឺកំពុងបង្រៀនកណ្តាលផ្តឹងផ្សែងៗនៃ
ព្រះវិហារៗ
លោកគ្រូ ម៉ឺធិន បានបង្រៀនពីព្រះ
គម្ពីរថា សារីរកប៉ុលមិនបាន
និយាយថា យើងអាចទទួល
បានទូវសេចក្តីសុចរិតតាមរយៈ
អំពើល្អដែលយើងធ្វើ
បានឡើយ...
ពេលដែលខ្ញុំឃល់
ឃើញចំណុចនេះ
ខ្ញុំក៏បានកើតជាថ្មី
ម្តងទៀតមែនៗ
...ប៉ុន្តែគឺសេចក្តីសុចរិត
ដែលព្រះជាម្ចាស់ប្រទាន
ឱ្យដោយឥតគិតថ្លៃទៅ
កាន់អស់អ្នកដែលមិន
មានសេចក្តីសុចរិតរបស់ខ្លួន
ពោលគឺសេចក្តីសុចរិត
ដែលមកពីក្រៅយើងនោះៗ


នៅមីក្រង់ដឹងតិនបើប្អូ ឈាកហ្ស ម៉ាមិន ក៏បានធ្វើសាសង្ឃម្នាក់ដែរ។
ក្មានការលន់តួថ្ងៃនេះទេ...
ប្អូនអាចចាប់ផ្តើមលន់តួបាន
...ប៉ុន្តែ ខ្ញុំចង់ប្តូរលិខិតលោះបាបកម្ម!
ចំណាំម៉ាការសម្រាប់លោះបាបកម្ម
ចុះអ្នកបានលិខិតប្បីងមកពីណា?
ខ្ញុំបានពី...
លោក យូហាន ធេតសើល (Johann Tetzel)
សាច់ញាតិវិលស្លាប់របស់អ្នកកំពុងតែរង់ចាំ...
បុគ្គលវិលស្រឡាញ់កាត់ល្មមគ្រប់គ្រាន់...
ទឹម ១ ជាង ២ ដឹងណាមាត់ទេ?
ទឹម ៤ ថែម ១ ដោយគ្មានពិគណ្នា!
តើម្តេចដែរឲ្យគាត់មានលេងីគាត។
កុំរស់នៅដោយមានពិរុទ្ធភាពដោយសារមិនបានសួរ!
ចូលចាំថា...
ពេលសំឡេងកាក់បន្លឺល្មមឡើងក្តាំង ហឹប នោះព្រលឹងនឹងលោះចេញពីស្ថានឧភ។
ក៏... ក៏ខ្ញុំមិនអាចរស់ដោយមានពិរុទ្ធភាពបានឡើយ។
ក្មានឲ្យស្លាប់ណាស់!


តើគាត់គិតថាខ្លួនជានរណា?
ការធ្វើបែបនេះគឺគួរឱ្យអាក្រក់ណាស់!
លក់លិខិតឈ្មោះជាបាបកម្ម ដើម្បីរកការចំណេញ!
គាត់កំពុងតែមើលងាយព្រះជាម្ចាស់ហើយ។
ខ្ញុំនឹងលើកទឹកចិត្តឱ្យមានការប្រកាសាសនាណា...
...ដើម្បីរងរំខានអ្នកឯទៀតអំពីនិក្ខេបបទនេះ...
...ក្នុងរបៀបដ៏ឯកសណ្ឋាន។


ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៨១៧
ជាំង!
ជាំង!
ជាំង!

ការដែលលោកគ្រូ ម៉ឺធិន លូសើរ បិទនិក្ខេបបទ ៩៥ គឺមិនមែនជាសកម្មភាពនៃការឆ្លងទឹងប្រថាំង ឬក៏ជាការដែលគាត់ចង់ចាប់ផ្តើមបដិវត្តន៍នោះទេ។ គាត់គ្រាន់តែចង់លើកទឹកចិត្តឲ្យមានការជជែកគ្នាទាក់ទងនឹងប្រធានបទនៃការលក់លិខិតលោះបាបកម្មក្នុងក្រុមជំនុំតែប៉ុណ្ណោះ។

គេបានបដិសេធសំណើរបស់លោកគ្រូ លូសើរ ដើម្បីឲ្យមានការជជែកគ្នា។ មិនយូរប៉ុន្មានបន្ទាប់ពីគាត់បានបិទនិក្ខេបបទទាំងអស់នោះ គេក៏បានបកវាចេញពីទ្វា ហើយបានសរសេរចម្លងជាច្រើន និងក៏បានផ្សព្វផ្សាយពាសពេញអឺរ៉ុប។ និក្ខេបបទ ៩៥ របស់លោកគ្រូ លូសើរ ដែលគាត់បានបិទក៏បានសាយភាយទៅដល់ទីក្រុងរ៉ូម ហើយក៏បានទាក់ទាញចំណាប់អារម្មណ៍សម្តេច ប៉ុប។ គេក៏បានកោះហៅលើកសវនាការមួយដោយសង្ឃឹមថាលោកគ្រូ លូសើរ នឹងដកចេញនូវសម្តីនៃការនិពន្ធរបស់គាត់ចោល ប៉ុន្តែគាត់មិនបានធ្វើដូច្នោះទេ។

កណ្ឌគម្ពីរ អេភេសូរ ២:៨-៩ បានលើកឡើងថា «ដ្បិតដោយសារព្រះគុណ អ្នករាល់គ្នាបានសង្គ្រោះតាមរយៈជំនឿ ហើយសេចក្តីនេះមិនមែនមកពីអ្នករាល់គ្នាទេ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ដើម្បីកុំឲ្យអ្នកណាម្នាក់អួតខ្លួន» (គកស)។ លោកគ្រូ លូសើរ បានជឿថាការរាប់ជាសុចរិតចេញពីអំពើបាបកើតឡើងតែតាមរយៈជំនឿ តែមួយគត់ លើព្រះគ្រីស្ទតែមួយអង្គគត់ ក្រៅពីការប្រព្រឹត្ត។ គាត់បានបដិសេធសេចក្តីបង្រៀនរបស់ក្រុមជំនុំកាតូលិក ដែលជឿថាការរាប់ជាសុចរិតគឺតាមរយៈជំនឿ និងការប្រព្រឹត្តដែលកើតចេញពីកាយវិការដែលទទួលស្គាល់ថាខ្លួនបានធ្វើខុស។ ដោយសារជំនឿរបស់គាត់ប្រឆាំងគ្នានឹងសេចក្តីបង្រៀនរបស់ក្រុមជំនុំកាតូលិក នោះគេក៏បានបង្ខំលោកគ្រូ លូសើរ ឲ្យដកសេចក្តីបង្រៀនរបស់គាត់ចេញជាថ្មីម្តងទៀត។ គឺនៅឯសវនាការនេះឯងដែលគាត់បានលើកឡើងថា «ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដក់នៅក្នុងសតិសម្បជញ្ញៈរបស់ខ្ញុំយ៉ាងជាប់»។

លោកគ្រូ ម៉ឺធិន លូសើរ បានបដិសេធដោយមិនប្តូរសេចក្តីជំនឿរបស់គាត់។ ដោយឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ គាត់ក៏បានលើកទឹកចិត្តដល់មនុស្សជាច្រើននៅអឺរ៉ុបឲ្យធ្វើដូចគាត់ដែរ។

ផ្នែកទី២៖

ការនិយាយបំផ្លើសពីរប្រវត្តិសាស្ត្រក្រមជំនុំ

លោកគ្រូ អហ្គស្ទីន ពីទីក្រុងហិបផូ (Augustine of Hippo)

ឆ្នាំ ៣៥៤-៤៣០

លោកគ្រូ អហ្គស្ទីន ដែលជាគ្រូនៅជំនាន់ដើមនៃក្រុមជំនុំ គឺជាអ្នកមានការកិច្ចយ៉ាងខ្លាំងក្នុងការបង្កើតគ្រីស្ទសាសនានៅលោកខាងលិច។ ការបង្រៀនរបស់គាត់បានជះឥទ្ធិពលយ៉ាងខ្លាំងក្នុងការនាំឲ្យមានការកែទម្រង់ខាងឯព្រះវិហារ។

ធនធានខ្លះៗរបស់លោកគ្រូ អហ្គស្ទីនៈ

- *ការលន់តួរបស់លោកគ្រូ អហ្គស្ទីន*
- *The City of God*



លោកគ្រូ ចន វ៉ែកល្លែវ (John Wycliffe)

ឆ្នាំ ១៣២០-១៣៨៤

គេស្គាល់ថាជា «ផ្កាយរះនៃការកែទម្រង់» លោកគ្រូ ចន វ៉ែកល្លែវ បានទាស់ប្រឆាំងនឹងអំណាចថ្នាក់ដឹកនាំ [ខាងក្រុមជំនុំកាតូលិក] ជាអ្នកនាំមុខក្រុមបកប្រែព្រះគម្ពីរចេញពីភាសាឡាតាំងទៅជាភាសាអង់គ្លេស ហើយក៏បានផ្ទៀបឆាកសម្រាប់ឲ្យការកែទម្រង់បានកើតឡើង។



លោកគ្រូ យូន ហឺស៍ (Jan Hus)

ឆ្នាំ ១៣៧២-១៤១៥

ទទួលការជះឥទ្ធិពលនៃទស្សន:ពីគោលជំនឿរបស់លោកគ្រូ ចន វ៉ែកឡេវ ដូច្នេះហើយបានជាលោកគ្រូ ហឺស៍ អធិប្បាយប្រឆាំងនឹងក្រុមជំនុំកាតូលិក ដោយឲ្យតម្លៃលើព្រះបន្ទូលឲ្យមានអំណាចលើសប្រពៃណីរបស់ក្រុមជំនុំ កាតូលិកនេះ។ នៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៤១៥ គេបានដុតសម្លាប់គាត់ នៅឯបង្គោលភ្លើង។

ឆន្ទឆានខ្លះៗរបស់លោកគ្រូ យូន ហឺស៍៖

- The Church



លោកគ្រូ យូហានណាស៍ ហ្គូតិនបើត (Johannes Gutenberg)

ឆ្នាំ ១៣៩៨-១៤៦៨

ការមានម៉ាស៊ីនថតចម្លងនាំឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅអឺរ៉ុបទាក់ទងនឹងការផ្សព្វផ្សាយស្នាដៃនៃការនិពន្ធ។ បច្ចេកវិជ្ជារបស់លោកគ្រូ ហ្គូតិនបើគ ត្រូវបានគេប្រើប្រាស់ក្នុងការបោះពុម្ព និងការចែកចាយនិក្ខេបបទ ៩៥ របស់លោកគ្រូ លូសើរ ដែលតាមរយៈការនោះវាបាននាំឲ្យមានកំណែទម្រង់កើតឡើង។



លោកគ្រូ ម៉ាធិន លូសើរ (Martin Luther)

ឆ្នាំ ១៤៨៣-១៥៤៦

នៅថ្ងៃទី ៣១ ខែតុលា លោកគ្រូ លូសើរ បានលើកឡើង ៩៥ ចំណុចដើម្បី
វាយប្រហារលើការប្រើប្រាស់ការលក់លិខិតលោះបាបកម្ម។ គេបានចែក
ចាយនិក្ខេបបទ ៩៥ ទាំងនោះពាសពេញប្រទេស ហើយវាក៏បានសាយ
ភាយទៅដល់ទីក្រុងរ៉ូម។ គេបានចាត់ទុកការនេះថាជាផ្កាភ្លើងមួយដែលធ្វើ
ឲ្យកំណែទម្រង់នេះឆាបឆេះឡើង។

ធនធានខ្លះៗរបស់លោកគ្រូ ម៉ាធិន លូសើរ៖

- *95 Theses*
- *The Bondage of the Will*


ឱ! ធីក្រែងអ៊ុមអើយ!
ការបោកបញ្ឆោតរបស់ឯង
ត្រូវធីបញ្ចប់ហើយ!
និក្ខេបបទ ៩៤

លោកគ្រូ ហូលឌ្រិត ស្វីងហ្គ្លីលី (Huldrych Zwingli)

ឆ្នាំ ១៤៨៤-១៥៣១

«ទំនុកចិត្តរបស់យើងលើព្រះគ្រីស្ទមិនធ្វើឲ្យយើងខ្ជិល មិនអើពើ ឬក៏មិនរឹរវល់ឡើយ ប៉ុន្តែផ្ទុយទៅវិញវាពង្រាក់ស្មារតីរបស់យើង ជំរុញយើងឲ្យបន្ត ហើយធ្វើអោយយើងសកម្មក្នុងការរស់នៅដ៏សុចរិត និងប្រព្រឹត្តអំពើល្អទៅវិញ។ គ្មានទំនុកចិត្តលើខ្លួនឯងអាចយកមកប្រៀបធៀបនឹងចំណុចមួយនេះបានឡើយ។»



លោកគ្រូ វៀលឡាម ហ្វឺរែល (William Farel)

ឆ្នាំ ១៤៨៩-១៥៦៥

លោកគ្រូ ហ្វឺរែល បានបញ្ជុះបញ្ជូលលោកគ្រូ ចន ខិលវិន ឲ្យនៅទីក្រុង ហ្សឺណែវ (Geneva) បានពីរដង ដូច្នេះលោកគ្រូ ហ្វឺរែល ទំនងជាទទួលបានពិន្ទុច្រើនទាក់ទងនឹងភាពទាក់ទាញរបស់គាត់ ប្រសិនបើគាត់ជាបុគ្គលម្នាក់ដែលនៅបន្តមានតួនាទីក្នុងការលេងហ្គេមមួយនេះ។


រត្តដ្ឋ
២២

លោកគ្រូ វៀលឡាម ចិនដិល (William Tyndale)

ឆ្នាំ ១៤៩៤-១៥៣៦

លោកគ្រូ ចិនដិល គឺជាបុគ្គលដំបូងគេបង្អស់ដែលបានបកប្រែព្រះគម្ពីរទៅជាភាសាអង់គ្លេស ដោយប្រើប្រាស់ព្រះគម្ពីរភាសាហេប្រឺ និងភាសាក្រិក។ គេបានចោទគាត់ថាជាគ្រូខុសឆ្គង ហើយក៏បានសម្លាប់គាត់ដោយច្របាច់ក ហើយបន្ទាប់មកគេយកសពរបស់គាត់ទៅដុតនៅឯបង្គោលភ្លើង។



លោកគ្រូ ភីលីព ម៉ាឡង្គជថូន (Philip Melanchthon)

ឆ្នាំ ១៤៩៧-១៥៦០

ទោះលើគេបានរាប់គាត់ថា ជាបុគ្គលម្នាក់ដែលមានការប្រុងប្រយ័ត្ន ហើយ ចូលចិត្តសន្តិភាព ក៏លោកគ្រូ ម៉ាឡង្គជថូន នៅមានភាពក្លាហានគ្រប់គ្រាន់ ក្នុងការក្រោកឈរ ដើម្បីទាស់ប្រឆាំងនឹងក្រុមជំនុំកាតូលិកជាមួយនឹងលោក គ្រូ លូសើរ នៅក្នុងការកែទម្រង់ដែរ។ ពួកគាត់ក៏បានបង្កើតប្រពៃន្ធទេវវិទ្យា លូទីនជាមួយគ្នា (Lutheran theology)។

ធនធានខ្លះៗរបស់លោកគ្រូ ម៉ាឡង្គជថូន៖

- *The Apology of the Augsburg Confession*



លោកគ្រូ ចន ខិលវិន (John Calvin)

ឆ្នាំ ១៥០៩-១៥៦៤

លោកគ្រូ ចន ខិលវិន បានបង្កើតប្រពៃន្ធទេវវិទ្យា (ដែលឥឡូវនេះយើងហៅថា “Calvinism” ដែលមានន័យថា «ខិលវិននិយម») ដោយពឹងលើការបង្រៀនរបស់លោកគ្រូ អហ្គស្ទីន និងអ្នកដទៃនៅឯជំនាន់ក្រុមជំនុំដំបូង។ លោកគ្រូ ខិលវិន បានផ្តោតយ៉ាងខ្លាំងលើប្រធានបទអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ក្នុងគ្រប់អ្វីៗទាំងអស់។

ធនធានខ្លះៗរបស់លោកគ្រូ ខិលវិន៖

- *The Institutes of the Christian Religion*


វិទ្យាល័យនរៈ
ម្ចាស់ផ្ទាំងគ្រែ:

លោកគ្រូ ធីអូដ័រ ប៊ីសា (Theodore Beza)

ឆ្នាំ ១៥១៩-១៦០៥

ទទួលតំណែងបន្តពីលោកគ្រូ ខិលវិន ហើយក៏ជាបុគ្គលដែលមានលក្ខណៈស្ទើរតែដូចគ្នាលេះបិទនឹងលោកគ្រូ ខិលវិន ផងដែរ។

ធនធានខ្លះៗរបស់លោកគ្រូ ធីអូដ័រ ប៊ីសា៖

- *The Life of John Calvin*
- *The Christian Faith*



លោកគ្រូ ចន នូស៍ (John Knox)

ឆ្នាំ ១៥១៩-១៦០៥

គាត់ជាអ្នកដឹកនាំដែលហ៊ាននិយាយអំពីកំណែទម្រង់ប្រូតេស្តង់នៅប្រទេសស្កុឡិន (Scotland) លោកគ្រូ នូស៍ មានភាពក្លាហានក្នុងការប្រឆាំងនឹងបញ្ហាផ្នែកនយោបាយ និងផ្នែកសាសនា ដោយប្រថុយជីវិតគាត់ក្នុងគ្រោះថ្នាក់។ គំនិតរបស់គាត់បានជួយបង្កើតក្រុមជំនុំព្រេសប៊ីធេរាន។

ធនធានខ្លះៗរបស់លោកគ្រូ នូស៍៖

- *The History of the Reformation in Scotland*


BOLLOCKS!

លោកគ្រូ ចន ហ្វីស៍ (John Foxe)

ឆ្នាំ ១៥១៦-១៥៨៧

ក្នុងនាមជាប្រវត្តិវិទូម្នាក់លោកគ្រូ ហ្វីស៍ បានកត់ត្រាចុះអំពីគ្រីស្ទបរិស័ទ
ដែលក្រុមជំនុំកាតូលិកបានសម្លាប់ចោល។

ធនធានខ្លះៗរបស់លោកគ្រូ ចន ហ្វីស៍៖

- *Foxe's Book of Martyrs*



លោកគ្រូ ចន អូវិន (John Owen)

ឆ្នាំ ១៦១៦-១៦៨៣

ពេលមានអាយុ ១៩ ឆ្នាំគាត់បានទទួលសញ្ញាបំត្របណ្ឌិត ហើយបន្ទាប់មក បានក្លាយជាគ្រូគង្វាលសម្រាប់ក្រុមជំនុំ និងសម្រាប់កងទំព័ នាយកមហាវិទ្យាល័យ និងជាអ្នកនិពន្ធដ៏ឆ្នើមម្នាក់។

ធនធានខ្លះៗរបស់លោកគ្រូ ចន អូវិន៖

- *The Death of Death in the Death of Christ*
- *The Mortification of Sin*
- *Communion with God*
- *The Divine Power of the Gospel*



លោកគ្រូ ចន ប៊ុនយ៉ាន (John Bunyan)

ឆ្នាំ ១៦២៨-១៦៨៨

គេបានដាក់គុកលោកគ្រូ ប៊ុនយ៉ាន អស់រយៈពេល ១២ ឆ្នាំ ដោយសារគាត់បដិសេធមិនព្រមឈប់អធិប្បាយ។ ពេលដែលគេបានដាក់គុកគាត់ជាលើកដំបូង គាត់បាននិពន្ធសៀវភៅ «ផ្លូវទៅឯស្ថានសួគ៌» (The Pilgrim's Progress)។

ធនធានខ្លះៗរបស់លោកគ្រូ ចន ប៊ុនយ៉ាន៖

- *ផ្លូវទៅឯ ស្ថានសួគ៌*
- *Grace Abounding to the Chief of Sinners*



លោកគ្រូ ម៉ាថាយ ហិនរី (Matthew Henry)

ឆ្នាំ ១៦៦២-១៧១៤

«ព្រះជាម្ចាស់បានបង្កើតស្ត្រីចេញពីឆ្អឹងជំនីរនៃចំហៀងរបស់លោក អ័ដាម។ មិនមែនចេញពីក្បាលរបស់គាត់ ដើម្បីត្រួតត្រាលើគាត់។ ហើយក៏មិនមែនចេញពីជើងរបស់គាត់ ដើម្បីឲ្យគាត់ជិះជាន់នាងនោះទេ។ ប៉ុន្តែ ចេញពីចំហៀងរបស់គាត់ ដើម្បីឲ្យមានភាពស្មើគ្នា ចេញពីក្រោមដៃរបស់គាត់ ដើម្បីឲ្យគាត់ការពារនាង ហើយនៅក្បែរបេះដូងរបស់គាត់ ដើម្បីឲ្យគាត់ស្រឡាញ់នាង។»

(ដកស្រង់ចេញពីៈ សេចក្តីអត្ថាធិប្បាយរបស់លោកគ្រូ ម៉ាថាយ ហិនរី លើកណ្ឌកថ្មីរលោកុប្បត្តិ៣ក៖២)

ធនធានខ្លះៗរបស់លោកគ្រូ ម៉ាថាយ ហិនរីៈ

- Matthew Henry's 6 Volume Commentary on the Whole Bible



លោកគ្រូ យ៉ូណាថាន អេឌវឺដស៍ (Jonathan Edwards)

ឆ្នាំ ១៧០៣-១៧៥៨

លោកគ្រូ អេឌវឺដស៍ ជាអ្នកដឹកនាំដ៏សំខាន់ម្នាក់ក្នុងការភ្ញាក់ខ្លួនដ៏អស្ចារ្យលើកដំបូង (the 1st Great Awakening)។ គាត់គឺជាទេវវិទូខាងផ្នែកពួកព្យួរីតិន (Puritan) ហើយក៏ជាអ្នកប្រកាន់ខ្ជាប់ទេវវិទ្យាកែទម្រង់ផងដែរ (Reformed Theology)។

ធនធានខ្លះៗរបស់លោកគ្រូ យ៉ូណាថាន អេឌវឺដស៍៖

- *Sinners in the Hands of an Angry God*
- *The End for Which God Created the World*
- *The Life of David Brainerd*
- *Religious Affections*


ភ្ញាក់ផ្អើល!!
ព្រះគម្ពីរ

លោកគ្រូ ជច វែកហ្វៀលឌ៍ (George Whitefield)

ឆ្នាំ ១៧១៤-១៧៧០

ជាមួយគ្នានឹងលោកគ្រូ ចន ផស្លី (John Wesley) លោកគ្រូ ជែកហ្វៀលឌ៍ គឺជាស្ថាបនិកម្នាក់នៃក្រុមនិកាយមេតូឌីស្ត។ ការដែលលោកគ្រូ ជែកហ្វៀលឌ៍ បានអធិប្បាយតាមកន្លែងសាធារណៈបានជួយឲ្យមានការភ្ញាក់ខ្ពុនដ៏អស្ចារ្យ រាលដាលឡើងនៅប្រទេសអាមេរិក។

ធនធានខ្លះៗរបស់លោកគ្រូ ជច វែកហ្វៀលឌ៍ៈ

- *Sermons of George Whitefield*
- *Whitefield's Letter to Wesley on Election*



លោកគ្រូ ចន ញ៉ូតិន (John Newton)

ឆ្នាំ ១៧២៥-១៨០៧

មុនពេលដែលលោកគ្រូ ចន ញ៉ូតិន និពន្ធទំនុក «ព្រះគុណអស្ចារ្យ» គាត់គឺជាប្រធាននាវាម្នាក់ដែលដឹកជញ្ជូនទាសករ។ ខណៈពេលដែលគាត់កំពុងតែបើកបរនាវាក្នុងព្យុះមួយ គាត់ក៏បានទទួលសេចក្តីសង្គ្រោះតាមរយៈព្រះគុណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ គាត់ក៏បានលាចេញពីការជួញដូរមនុស្ស ហើយចូលក្រុមចលនានៃការគាំទ្រក្នុងការលុបចោលការជួញដូរមនុស្ស (Abolitionist Movement)។

ធនធានខ្លះៗរបស់លោកគ្រូ ចន ញ៉ូតិន៖

- *Out of the Depths*
- *Letters of John Newton*



លោកគ្រូ ឆាលស៍ ហែតជ៍ (Charles Hodge)

ឆ្នាំ ១៧៩៧-១៨៧៨

«គោលជំនឿនៃព្រះគុណនាំឲ្យបុរសម្នាក់នេះបន្ទាបខ្លួន ដោយមិនបន្ទាប
បន្តោកគាត់ ហើយលើកតម្កើងគាត់ ដោយមិនធ្វើឲ្យគាត់មានអំនួត។»

«ភស្តុតាងដ៏ល្អបំផុតរបស់ព្រះគម្ពីរត្រង់ថាព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះ
ជាម្ចាស់លើយថា វាស្ថិតក្នុងចន្លោះកណ្តាលនៃគម្របរបស់វា។ វាគឺជាភស្តុ-
តាងសម្រាប់ខ្លួនឯងផ្ទាល់។»

ធនធានខ្លះៗរបស់លោកគ្រូ ឆាលស៍ ហែតជ៍៖

- *Systematic Theology*



លោកគ្រូ ជច មុឡឺរ (George Müller)

ឆ្នាំ ១៨០៥-១៨៩៨

«នៅត្រង់នេះព្រះជាម្ចាស់បានប្រទានបេសកកម្មដល់ខ្ញុំ ដូច្នេះខ្ញុំនឹងរស់ ហើយស្លាប់នៅកន្លែងនេះ។»

ក្នុងឆាកជីវិតរបស់លោកគ្រូ មុឡឺរ គាត់បានមើលថែក្មេងកំព្រាអស់ ១០.០០០ នាក់ដោយមិនដែលហាមាត់សុំជំនួយ។ តែផ្ទុយទៅវិញ គាត់បានទុកចិត្តលើព្រះអម្ចាស់ថា ទ្រង់នឹងផ្គត់ផ្គង់នូវរាល់តម្រូវការទាំងអស់។

ធនធានខ្លះៗរបស់លោកគ្រូ ជច មុឡឺរ៖

- *George Muller: Convictions and Teachings*
- *George Muller: My Journal*



លោកគ្រូ ចេ. ស៊ី. រ៉ៃល (J. C. Ryle)

ឆ្នាំ ១៨១៦-១៩០០

ដោយមានទឹកចិត្តចង់ប្រកាសដំណឹងល្អទៅកាន់រាល់គ្រប់ជាតិសាសន៍ លោកគ្រូ រ៉ៃល ក៏បានធ្វើជាអ្នកនាំមុខក្នុងការដាំក្រុមជំនុំតាមតំបន់ដាច់ស្រយាល។

ធនធានខ្លះៗរបស់លោកគ្រូ ចេ. ស៊ី. រ៉ៃល៖

- *Holiness*
- *Expository Thoughts on the Gospels*
- *Practical Religion*



លោកគ្រូ ឆាលស៍ ហេដិន ស្ពឺចិន (Charles Haddon Spurgeon)

ឆ្នាំ ១៨៣៤-១៨៩២

គេបានចាត់ទុកលោកគ្រូ ស្ពឺចិន ថាជា «អ្នកអធិប្បាយដ៏ធ្ងៃមជាងគេបង្អស់»។ គាត់បានសរសេរសេចក្តីអត្ថាធិប្បាយរាប់ពាន់ច្បាប់ និងសៀវភៅជាច្រើន។

«ចំពោះលោកអ្នក ប្រសិនលើព្រះគ្រីស្ទមិនមែនជាអ្វីៗទាំងអស់ នោះទ្រង់ក៏គ្មានតម្លៃអ្វីដែរចំពោះលោកអ្នក។ ទ្រង់នឹងមិនដែលចាប់ដៃគ្នាជាលក្ខណៈនៃផ្នែកមួយនៃព្រះសង្គ្រោះចំពោះមនុស្សលោកទេ។ ប្រសិនលើទ្រង់ជាអ្វីមួយដាច់ខាតទ្រង់ត្រូវតែជាអ្វីគ្រប់បែបយ៉ាង ហើយប្រសិនលើទ្រង់មិនមែនជាអ្វីគ្រប់បែបយ៉ាងនោះទេ នោះទ្រង់មិនមែនជាអ្វីមួយចំពោះលោកអ្នកឡើយ។»

«មានការលំបាកក្នុងរកគ្រប់អ្វីៗទាំងអស់លើកលែងតែការញ៉ាំនំចាក់ចុល។»

ធនធានខ្លះៗរបស់លោកគ្រូ ស៊ី. អេច. ស្ពឺចិន៖

- *Morning and Evening (adevotional)*
- *All of Grace*
- *The Wordless Book*



លោកគ្រូ ប៊ី. ប៊ី. វ័រហ្វៀល (B. B. Warfield)

ឆ្នាំ ១៨៥១-១៩២១

លោកគ្រូ វ័រហ្វៀល ជឿលើអំណាចនៃព្រះបន្ទូល និងការដែលព្រះជាម្ចាស់បណ្តាលឲ្យអ្នកនិពន្ធតែងព្រះបន្ទូល។ គាត់ជំទាស់នឹងទេវវិទ្យាទំនើប (Modernist Theology) ដែលបង្រៀនថា ព្រះជាម្ចាស់មិនបានបណ្តាលឲ្យអ្នកនិពន្ធតែងព្រះគម្ពីរទេ។

ធនធានខ្លះៗរបស់លោកគ្រូ ប៊ី. ប៊ី. វ័រហ្វៀល៖

- *The Inspiration and Authority of the Bible*




លោកគ្រូ ជេ. ហ្គ្រេសាំម ម៉ាឆិន (J. Gresham Machen)

ឆ្នាំ ១៨៨១-១៩៣៧

ដោយសារលោកគ្រូ ម៉ាឆិន មានការស្អប់ខ្ពើមទេវវិទ្យាបែបសេរីភាពនិយម គាត់ក៏បានបង្កើតសាលាគម្ពីរ ផនមីនស្ទឺរ (Westminster Seminary) និង ក្រុមជំនុំព្រេសប៊ីធេរានគោលលទ្ធិត្រឹមត្រូវ (Orthodox Presbyterian Church)។

លោកគ្រូ ជេ. ហ្គ្រេសាំម ម៉ាឆិន (J. Gresham Machen)

- *Christianity and Liberalism*



លោកគ្រូ អេ. ដាប់ប៊ិលយូ. ភីងខ៏ (A. W. Pink)

ឆ្នាំ ១៨៨៦-១៩៥២

បន្ទាប់ពី លោកគ្រូ ខធើរវិគកិងតិន ភីងខ៏ (Arthur Walkington Pink) ឃើញថាគាត់មិនមានអំណោយទានក្នុងការអធិប្បាយ គាត់ក៏បានដកខ្លួនចេញ ហើយចំណាយពេលនិពន្ធសៀវភៅទៅវិញ។

ធនធានខ្លះៗរបស់លោកគ្រូ អេ. ដាប់ប៊ិលយូ. ភីងខ៏

- *The Sovereignty of God*
- *The Attributes of God*


លោកគ្រូ ម៉ាតិន ឡយ៉ដ-ជូស៍ (Martyn Lloyd-Jones)

ឆ្នាំ ១៨៩៩-១៩៨១

ដោយឈរលើមូលដ្ឋាននៃអំណាចរបស់ព្រះបន្ទូលលោកគ្រូ ម៉ាតិន ឡយ៉ដ-ជូស៍ លើកទឹកចិត្តក្រុមជំនុំរបស់គាត់ឲ្យមានភាពឆេះឆួល និងការយល់ដឹងអំពីព្រះគម្ពីរ។តាមរយៈការកាត់ស្រាយព្រះបន្ទូលក្នុងសេចក្តីអត្ថាធិប្បាយរបស់គាត់ គាត់បានប្រកាសព្រះបន្ទូលដោយមានការលាយឡំទាំងតក្កវិទ្យា និងអណ្តាតភ្លើងនៃភាពឆេះឆួល។

ធនធានខ្លះៗរបស់លោកគ្រូ ម៉ាតិន ឡយ៉ដ-ជូស៍៖

- *Preaching and Preachers*


ពក្កវិទ្យា

ធនធានដែលយើងបានប្រើប្រាស់សម្រាប់ការបង្កើតឯកសារអប់រំទាក់ទងនឹងលោកគ្រូ ម៉ាធិន លូសើរ៖

- http://www.luther.de/en/index.html

- https://en.wikipedia.org/wiki/Martin_Luther

- http://martinluther.ccws.org/index.html

- https://www.britannica.com/biography/Martin-Luther

- Sproul, R. C. (2011, November 21). Luther and the Reformation. Audio mp3 retrieved from http://www.ligonier.org/store/luther-and-the-reformation-cd/

ធនធានដែលយើងបានប្រើប្រាស់សម្រាប់ជាព័ត៌មានទាក់ទងនឹងការនិយាយបំផ្លើស៖

- https://www.theopedia.com/

- https://www.wikipedia.org/

- https://www.goodreads.com/quotes

- http://mljtrust.org/

- http://www.ccel.org/f/foxe/martyrs/home.html

- Janet & Geoff Benge. Christian Heroes: Then and Now GEORGE MULLER The Guardian of Bristol's Orphans. YWAM Publishing, 2014

សេចក្តីថ្លែងអំណរគុណ

លោក ជីហ្វ ឡានជិន (Jeff Landon) ដែលធ្វើការនៅក្រុម Missional Wear—ភ្នុកអប់រំលោកគ្រូ ម៉ាធិន លូសើរ នឹងមិនអាចកើតឡើងបានឡើយប្រសិនបើលោក ឡានជិន មិនបានទាក់ទងមកកាន់ខ្ញុំដោយផ្តល់គំនិតឱ្យខ្ញុំបង្កើតភ្នុកអប់រំអំពីលោកគ្រូ ម៉ាធិន លូសើរ សម្រាប់ក្រុម Inktober។

ក្រុម Kickstarter backers—សៀវភៅមួយនេះនឹងមិនអាចកើតឡើងបានឡើយ បើក្រុមអ្នកមិនបានគាំទ្រ។ សូមអរគុណ!

ភរិយាខ្ញុំ និងកូនៗប្អូនៗនាក់របស់ខ្ញុំ—បានលើកទឹកចិត្តខ្ញុំឱ្យខិតខំប្រឹងប្រែងធ្វើការឱ្យអស់ពីសមត្ថភាព ពោលគឺមិនទទួលយកលទ្ធផលលំៗឡើយ។